ANNA & ASSOCIATES
Law Office

# ព័ត៌មានថ្មីៗ – ការទទួលផលចោរកម្ម និង ការប្រឆាំងនឹងអ្នករាជការសាធារណៈ

## ការបកស្រាយអំពី សកម្មភាពនៃការទទួលផលចោរកម្ម និងការប្រឆាំងជាមួយនឹងអ្នករាជការសាធារណៈ

*ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៦ – រាជធានីភ្នំពេញ – ព្រះរាជាណាចក្រកម្ពុជា*

ករណីដែលមានបុគ្គល «ក» បានទិញរថយន្តពីបុគ្គល «ខ» ដែលរថយន្តនោះត្រូវបានលួចពីអ្នកដទៃ ហើយបុគ្គល «ក» ក៏បានដឹងថារថយន្តនោះបានមកពីការលួច តែនៅតែទទួលទិញរថយន្តនោះ។ មិនតែប៉ុណ្ណោះ បុគ្គល «ក» បានធ្វើសកម្មភាពទិញរថយន្តដែលបានមកពីការលួចនេះជាទម្លាប់ ព្រោះមានតម្លៃថោកជាងទីផ្សារ។

នៅថ្ងៃមួយ ប៉ូលីសបានធ្វើចុះចាប់បុគ្គល «ខ» ដោយសារបុគ្គលនោះហេតុបានប្រព្រឹត្តបទល្មើស (អំពើលួច) ក៏ប៉ុន្តែបុគ្គល «គ» បានទៅតទល់ជាមួយប៉ូលីស ដោយយករនាំងដែកមកឡោមព័ទ្ធឡាន ចាក់បំបែកកង់ឡាន និងវាយបំផ្លាញឡានរបស់ប៉ូលីស ដើម្បីរាំងការបំពេញការងាររបស់ពួកគាត់(ចាប់ជនល្មើស)។

(១) តើអំពើរបស់បុគ្គល «ក» ដែលបានទទួលទិញរថយន្តទាំងដែលខ្លួនបានដឹងថារថយន្តនោះបានមកពីការលួចហើយបានធ្វើអំពើនោះជាទម្លាប់ និង (២) អំពើរបស់បុគ្គល «គ» ដែលបានទៅតតាំងដោយហិង្សាជាមួយប៉ូលីស គឺជាបទល្មើសព្រហ្មទណ្ឌដែរឬទេ?

សូមរំលឹកផងដែរថា ដើម្បីអាចចោទប្រកាន់ថាបុគ្គលណាមួយប្រព្រឹត្តបទល្មើសបាន លុះត្រាតែបុគ្គលនោះបានបំពេញជាតុផ្សំនៃបទល្មើសទាំង ៣(បី) ជាមុនសិនគឺ ជាតុនីត្យានុកូល(ច្បាប់មានចែងថាអំពើមួយជាបទល្មើស) ជាតុសត្យានុម័ត (សកម្មភាពដែលបង្កជាបទល្មើស) និងជាតុអត្តនោម័ត (ចេតនា ឬឆន្ទៈក្នុងការប្រព្រឹត្តបទល្មើស)។ ដូចនេះ នៅក្នុងអត្ថបទនេះយើងនឹងធ្វើការបកស្រាយទៅលើ **១. សកម្មភាពទទួលទិញវត្ថុដែលបានលួចពីអ្នកដទៃ** និង **២. ការប្រឆាំងដោយហិង្សាជាមួយប៉ូលីស** ដូចខាងក្រោម។

### ១. សកម្មភាពទទួលទិញវត្ថុដែលបានលួចពីអ្នកដទៃ

អំពើដែលបុគ្គល «ក» បានទទួលទិញរថយន្តដែលខ្លួនបាន «ដឹង» ថារថយន្តនោះគឺបានមកពីការលួចអ្នកដទៃ អំពើ ឬសកម្មភាពនេះ គឺជាបទល្មើសទទួលផលចោរកម្មដែលបានចែងក្នុងក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រម្ពុជាឆ្នាំ២០០៩ (**"ក្រមព្រហ្មទណ្ឌ"**)។

យោងតាម **មាត្រា ៣៩៩ និង មាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ** បានចែងថា៖

> *«អំពើទទួលផលចោរកម្ម គឺជាអំពើទទួល លាក់បំបាំង រក្សាទុក ឬបញ្ជូនវត្ថុអ្វីមួយ ដោយដឹងថាវត្ថុនេះបានមកពីបទឧក្រិដ្ឋ ឬបទមជ្ឈិម។»*
>
> *«ត្រូវចាត់ទុកជាអំពើទទួលផលចោរកម្មផងដែរ៖*



***ការបដិសេធ:*** *ព័ត៌មានដែលបានរៀបរៀងនៅក្នុងព្រឹត្តិបត្រគតិយុត្តរបស់អេណា គឺក្នុងគោលបំណងសម្រាប់ផ្តល់ជាព័ត៌មានតែប៉ុណ្ណោះ និងមិនផ្តោតសំខាន់ ទៅលើការប្រឹក្សាយោបល់ផ្នែកច្បាប់ឡើយ។ សូមធ្វើការកត់សម្គាល់ថា ការប្រឹក្សាផ្នែកច្បាប់ត្រូវធ្វើឡើង និងផ្តល់ជូនដោយមេធាវីប្រកបដោយសមត្ថភាព ព្រមទាំងគុណភាព ដែលធ្វើការប្រឹក្សាយោបល់ទៅលើគ្រប់ស្ថានភាពទាំងអស់។*

*១-អំពើធ្វើជាអន្តរការីដើម្បីបញ្ជូនវត្ថុអ្វីមួយ ដោយដឹងថារបស់នោះបានមកពីបទឧក្រិដ្ឋ ឬបទមជ្ឈិម។*

*២-អំពើដែលបានទទួលផលពីផលនៃ បទឧក្រិដ្ឋ ឬបទមជ្ឈិមដោយបានដឹងហេតុការណ៍ច្បាស់។*

*អំពើទទួលផលចោរកម្មត្រូវផ្តន្ទាទោសដាប់ពន្ធនាគារពីចន្លោះ ២ (ពីរ) ឆ្នាំ ដល់ ១០ (ដប់) ឆ្នាំ និង ពិន័យប្រាក់ពី ៤,០០០,០០០ រៀល ដល់ ១០,០០០,០០០ រៀល។ »*

មានន័យថា ការទទួលផលចោរកម្ម សំដៅទៅលើសកម្មភាពដែលយកវត្ថុនោះមកកាន់កាប់ (ទិញ ជួល ឬឱ្យគេ) ឬការយកទៅទុកនៅកន្លែងដែលគេរកមិនឃើញដើម្បីជួយបិទបាំងជនល្មើស ឬការទុកវត្ថុនោះនៅផ្ទះ នៅឃ្លាំង ឬក៏នៅក្នុងដៃរបស់ខ្លួន ឬជួយដឹកជញ្ជូនវត្ថុនោះពីកន្លែងមួយទៅកន្លែងមួយទៀត ដោយបាន «ដឹង» ថាវត្ថុនោះ បានមកការប្រព្រឹត្តបទឧក្រិដ្ឋ និងបទមជ្ឈិមដូចជា ការលួច ការរំលោភទំនុកចិត្ត ការឆបោកអ្នកដទៃជាដើម។ ចំពោះពាក្យថា **«វត្ថុនេះបានមកពីបទឧក្រិដ្ឋ ឬបទមជ្ឈិម»** មានន័យថា ទាល់តែវត្ថុនោះបានមកពីអំពើ ឬសកម្មភាព ដែលជាបទល្មើសច្បាប់ផ្តន្ទាទោសស្ថិតក្នុងចំណាត់ថ្នាក់ឧក្រិដ្ឋ ឬថ្នាក់មជ្ឈិម។ ករណីនៃការទទួល ផលដែលកើតចេញពីបទលហុវិញ មិនត្រូវចូលទៅក្នុងបទល្មើសទទួលផលចោរកម្មនោះទេ។ ដើម្បីយើងអាចដឹង ថា បទល្មើសណាមួយគឺជាបទលហុ បទមជ្ឈិម ឬបទឧក្រិដ្ឋ គេត្រូវមើលទៅលើការផ្តន្ទាទោសរបស់ច្បាប់ចំពោះ បទល្មើសនីមួយៗនោះ។ យើងអាចសម្គាល់ខ្លីៗដូចតទៅ បទលហុ គឺជាបទល្មើសទាំងឡាយណា ដែលច្បាប់ មានការផ្តន្ទាទោសដាក់ពន្ធនាគារជាអតិបរមា ក្នុងរយៈពេលក្រោម ឬស្មើនឹង ៦(ប្រាំមួយ) ថ្ងៃ។ ចំពោះបទមជ្ឈិម គឺជាបទល្មើសដែលច្បាប់មានការផ្តន្ទាទោសដាក់ពន្ធនាគារជាអតិបរមា លើសពី ៦ (ប្រាំមួយ) ថ្ងៃ និងក្រោម ឬ ស្មើនឹង ៥(ប្រាំ) ឆ្នាំ។ ចំណែកឯ បទឧក្រិដ្ឋ វិញ គឺជាបទល្មើសដែលច្បាប់មានការផ្តន្ទាទោសដាក់ពន្ធនាគារ ជាអតិបរមាលើសពី ៥(ប្រាំ) ឆ្នាំ និងក្រោម ឬស្មើនឹង៣០ (សាមសិប) ឆ្នាំ ឬអស់មួយជីវិត។

**ឧទាហរណ៍៖** ករណីមានច្បាប់បានចែងថាការលួចនូវទ្រព្យសម្បត្តិដែលមានតម្លៃតិចតួច (ចំណីអាហារ ឬរបស់ ប្រើប្រាស់ប្រចាំថ្ងៃ) គឺត្រូវទទួលទោសត្រឹមពិន័យជាប្រាក់ និងដាក់ពន្ធនាគារពី ១ថ្ងៃ ទៅ ៣ថ្ងៃ (បទលហុ)។ នៅ ក្នុងករណីនេះ បុគ្គលដែលបានទទួលយកវត្ថុដែលលួចនោះ មិនអាចត្រូវបានចោទប្រកាន់ថាជាអំពើទទួលផល ចោរកម្មនោះទេ ទោះបីជាបានដឹង ឬមិនបានដឹងថាវត្ថុនោះបានមកដោយសារលួចគេក៏ដោយ ព្រោះច្បាប់មិន បានចែង។ ក៏ប៉ុន្តែ តាមក្រមព្រហ្មទណ្ឌបច្ចុប្បន្ន អំពើលួច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ខែ ទៅ ៣ខែ (បទ មជ្ឈិម) និងមានការពិន័យជាប្រាក់ពី ១(ប្រាំមួយ) លាន ទៅ ៦ (ប្រាំមួយ) លាន ដូចនេះ វត្ថុដែលបានមកពី ការលួច ហើយមានបុគ្គលផ្សេងទទួលបន្តនោះដោយដឹងថាវត្ថុនោះមកពីការលួចនោះ ទើបអាចធ្វើការចោទ ប្រកាន់ថាជាអំពើទទួលផលចោរកម្ម។

បន្ថែមពីនេះ ចំពោះ **មាត្រា ៤០១ នៃក្រមព្រហ្មទណ្ឌ** ក៏បានចែងពីអំពើទទួលផលចោរកម្មនេះ ដែលត្រូវបាន ផ្តន្ទាទោសដាក់ពន្ធនាគារពី **៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ** កាលបើអំពើនេះត្រូវបានប្រព្រឹត្តឡើងនៅក្នុង លក្ខខណ្ឌណាមួយដូចខាងក្រោម៖

១. ជាទម្លាប់។

២. ដោយប្រើប្រាស់ភាពងាយស្រួលដែលផ្តល់ឱ្យដោយសកម្មភាពវិជ្ជាជីវៈរបស់ខ្លួន។

៣. ដោយមានការចាត់តាំងជាក្រុម។



***ការបដិសេធ:*** *ព័ត៌មានដែលបានរៀបរៀងនៅក្នុងព្រឹត្តិបត្រគតិយុត្តរបស់អេណា គឺក្នុងគោលបំណងសម្រាប់ផ្តល់ជាព័ត៌មានតែប៉ុណ្ណោះ និងមិនផ្តោត សំខាន់ ទៅលើការប្រឹក្សាយោបល់ផ្នែកច្បាប់ឡើយ។ សូមធ្វើការកត់សម្គាល់ថា ការប្រឹក្សាផ្នែកច្បាប់ត្រូវធ្វើឡើង និងផ្តល់ជូនដោយមេធាវីប្រកបដោយ សមត្ថភាព ព្រមទាំងគុណភាព ដែលធ្វើការប្រឹក្សាយោបល់ទៅលើគ្រប់ស្ថានភាពទាំងអស់។*

យោងតាមអង្គហេតុខាងលើវិញ បុគ្គល «ក» ដែលបានទទួលទិញរថយន្តដោយដឹងថាវត្ថុនោះបានកើតចេញពីអំពើលួច គឺជាអំពើទទួលផលចោរកម្ម ព្រោះថាបុគ្គលនេះបានបំពេញនូវធាតុផ្សំនៃបទល្មើសដែលច្បាប់ បានចែងថាអំពើទទួលនូវវត្ថុដែលកើតចេញពីការលួចនេះគឺជាបទល្មើស (ធាតុនីត្យានុកូល) សកម្មភាពទិញវត្ថុដែលបានពីការលួច (ធាតុនីត្យាកូល) និងការដឹងថាវត្ថុនោះបានមកពីការលួច ហើយនៅតែទទួលទិញវត្ថុនោះ (ធាតុអត្តនោម័ត)។ តាមអង្គហេតុខាងលើដោយសារបុគ្គល «ក» បានទិញជា «ទម្លាប់» នូវវត្ថុដែលបានមកពីការប្រព្រឹត្តបទល្មើស គឺជាស្ថានទម្ងន់ទោស។

ដូចនេះ អំពើ ឬសកម្មភាពបុគ្គល «ក» គឺជាបទល្មើសព្រហ្មទណ្ឌដែលអាចទទួលរងនូវការចោទប្រកាន់ និងផ្តន្ទាទោសក្រោមបទល្មើសទទួលផលចោរកម្ម ដែលមានស្ថានទម្ងន់ទោសចែងក្នុងមាត្រា ៤០១ នៃក្រមព្រហ្មទណ្ឌ។

## ២. ការប្រឆាំងដោយហិង្សាជាមួយប៉ូលីស

ចំពោះអំពើរបស់បុគ្គល «គ» ដែលបានតទល់ដោយហិង្សាជាមួយប៉ូលីស យកនាំងដែកមកឡោមព័ទ្ធឡាន ចាក់បំបែកកង់ឡាន និងវាយបំផ្លាញឡានរបស់ប៉ូលីសដើម្បីរារាំងការបំពេញការងាររបស់ពួកគាត់ អំពើ ឬសកម្មភាពនេះគឺជាបទល្មើសប្រឆាំងនឹងអ្នករាជការសាធារណៈ ដែលជាបទល្មើសព្រហ្មទណ្ឌដូចគ្នា។

យោងតាម **មាត្រា ៥០៣ នៃក្រមព្រហ្មទណ្ឌ** បានចែងថា៖

> *«ការប្រឆាំងនឹងអ្នករាជការសាធារណៈ គឺជាអំពើប្រឆាំងដោយប្រើការតទល់ដោយហិង្សានឹងអ្នករាជការសាធារណៈដែលធ្វើសកម្មភាពដើម្បីអនុវត្តច្បាប់ បញ្ជារបស់អាជ្ញាធរសាធារណៈ ឬសេចក្តីសម្រេចរបស់តុលាការ។*
>
> *បទប្រឆាំងនឹងអ្នករាជការសាធារណៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៣ (បី) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ៥០០.០០០ (ប្រាំសែន) រៀល»។*

អ្នករាជការសាធារណៈ សំដៅលើបុគ្គលទាំងឡាយណា ដែលធ្វើការឱ្យស្ថាប័នរដ្ឋទាំងអស់មិនថាជាមន្ត្រីក្របខណ្ឌ មន្ត្រីកិច្ចសន្យា ឬអ្នកតំណាងរាស្ត្រ (សមាជិករដ្ឋសភា/ព្រឹទ្ធសភា មន្ត្រីតាមខេត្ត ស្រុក និងមេឃុំ/ចៅសង្កាត់ជាដើម។ ពាក្យថា **«ការតទល់ដោយហិង្សា»** អាចជា សកម្មភាពរុញច្រាន វាយតប់ ប្រើអាវុធ ឬការប្រឆាំងដោយសកម្ម ដើម្បីរារាំងមន្ត្រី មិនឱ្យបំពេញការងារតាមច្បាប់បញ្ជា ឬកំណត់បាន។ សរុបជារួមមក មានន័យថា ការប្រឆាំងនឹងអ្នករាជការសាធារណៈ គឺជាសកម្មភាពដែលទៅធ្វើការតទល់ដោយអំពើ ឬសកម្មភាពហិង្សាដូចជាការវាយតប់ រុញច្រាន ឬការប្រឆាំងដោយសកម្ម ដើម្បីរារាំងមន្ត្រីដែលកំពុងអនុវត្តការងារស្របតាមច្បាប់។ បើយោងតាមមាត្រាខាងលើនេះ ការស្រែក ឬការតទល់ដោយមិនបានប្រើសកម្មភាពហិង្សាទៅលើអ្នករាជការសាធារណៈ ពុំត្រូវបានចោទប្រកាន់ពីបទប្រឆាំងនឹងអ្នករាជការសាធារណៈទេ។

ចំពោះអង្គហេតុខាងលើវិញ អំពើរបស់បុគ្គល «គ» បានបំពេញនូវធាតុផ្សំនៃបទល្មើសប្រឆាំងនឹងអ្នករាជការសាធារណៈ ព្រោះច្បាប់បានចែងថាអំពើតទល់ដោយហិង្សាជាមួយប៉ូលីសជាបទល្មើស (ធាតុនីត្យានុកូល)



***ការបដិសេធ:*** *ព័ត៌មានដែលបានរៀបរៀងនៅក្នុងព្រឹត្តិបត្រគតិយុត្តរបស់អេណា គឺក្នុងគោលបំណងសម្រាប់ផ្តល់ជាព័ត៌មានតែប៉ុណ្ណោះ និងមិនផ្តោតសំខាន់ ទៅលើការប្រឹក្សាយោបល់ផ្នែកច្បាប់ឡើយ។ សូមធ្វើការកត់សម្គាល់ថា ការប្រឹក្សាផ្នែកច្បាប់ត្រូវធ្វើឡើង និងផ្តល់ជូនដោយមេធាវីប្រកបដោយសមត្ថភាព ព្រមទាំងគុណភាព ដែលធ្វើការប្រឹក្សាយោបល់ទៅលើគ្រប់ស្ថានភាពទាំងអស់។*

ហើយសកម្មភាពដែលយករនាំងដែកមកឡោមព័ទ្ធឡាន ចាក់បំបែកកង់ឡាន និងវាយបំផ្លាញឡានរបស់ប៉ូលីស (ជាតុសត្យានុម័ត) ដោយមានចេតនារាំងមិនឱ្យប៉ូលីសធ្វើការចាប់ខ្លួនជនល្មើស (ជាតុអន្តោម័ត)។

ដូចនេះ អំពើ ឬសកម្មភាពរបស់បុគ្គល «គ» គឺជាបទល្មើសព្រហ្មទណ្ឌដែលអាចទទួលរងការចោទប្រកាន់ និងផ្តន្ទាទោសក្រោមបទល្មើសការប្រឆាំងនឹងរាជការសាធារណៈចែងក្នុងមាត្រា ៥០៣ នៃក្រមព្រហ្មទណ្ឌ។

## សេចក្តីសន្និដ្ឋាន

សរុបជារួមតាមការបកស្រាយខាងលើនេះ យើងអាចសន្និដ្ឋានបានថាបុគ្គល «ក» ដែលជាអ្នកទទួលទិញឡានដោយដឹងថាឡាននោះត្រូវបានលួចពីអ្នកដទៃ ហើយធ្វើវាជាទម្លាប់ អាចនឹងទទួលរងការចោទប្រកាន់ និងការផ្តន្ទាទោសចំពោះ បទល្មើសទទួលផលចោរកម្ម ដែលមានស្ថានទម្ងន់ទោសយោងក្នុង មាត្រា ៤០១ នៃក្រមព្រហ្មទណ្ឌ។ ចំណែកឯបុគ្គល «គ» វិញដែលបានចូលទៅប្រឆាំងតទល់ជាមួយប៉ូលីសដោយហិង្សាមានចេតនា និងឆន្ទៈក្នុងការរារាំងការងាររបស់ពួកគាត់ គឺអាចនឹងទទួលរងការចោទប្រកាន់ និងការផ្តន្ទាទោសចំពោះបទល្មើសប្រឆាំងនឹងអ្នករាជការសាធារណៈ តាម មាត្រា ៥០៣ នៃក្រមព្រហ្មទណ្ឌ។

**ទំនាក់ទំនងមកកាន់៖**

**ការិយាល័យមេធាវី អេណា និងសហការី**

**គេហទំព័រ**: www.anna-associates.com

**អ៊ីម៉ែល**: info@anna-associates.com

**លេខទូរស័ព្ទ**: (+៨៥៥) ៩៩ ៨៨៨ ៧៣៧

**អាសយដ្ឋាន៖**

**អាសយដ្ឋានការិយាល័យ**: អាគារលេខ២៣៤ ជាន់ទី៧ មហាវិថីម៉ៅសេទុង សង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា



***ការបដិសេធ:*** *ព័ត៌មានដែលបានរៀបរៀងនៅក្នុងព្រឹត្តិបត្រគតិយុត្តរបស់អេណា គឺក្នុងគោលបំណងសម្រាប់ផ្តល់ជាព័ត៌មានតែប៉ុណ្ណោះ និងមិនផ្តោតសំខាន់ ទៅលើការប្រឹក្សាយោបល់ផ្នែកច្បាប់ឡើយ។ សូមធ្វើការកត់សម្គាល់ថា ការប្រឹក្សាផ្នែកច្បាប់ត្រូវធ្វើឡើង និងផ្តល់ជូនដោយមេធាវីប្រកបដោយសមត្ថភាព ព្រមទាំងគុណភាព ដែលធ្វើការប្រឹក្សាយោបល់ទៅលើគ្រប់ស្ថានភាពទាំងអស់។*